

# PROMOTING HEALTHY BEHAVIORS (PHB) ACTIVITY

The Promoting Healthy Behaviors (PHB) Activity is a USAID funded Social and Behavior Change project that commenced in 2018. The goal of PHB is to improve health behaviors among Cambodians and ensure they seek and receive quality healthcare with decreased financial hardship. PHB initially targeted 6 key health areas: Maternal & Child Health; Nutrition; Water, Sanitation and Hygiene (WASH); Tuberculosis; Family Planning; and Malaria. In 2020-2021, PHB also implemented COVID-related activities in response to the global pandemic. Towards the end of 2021, noncommunicable diseases (NCDs) were added to PHB's health portfolio, and the project was extended until June 2025. PHB, implemented by Population Services International and its partners in collaboration with the Royal Government of Cambodia (RGC), works in six provinces: Phnom Penh, Kampong Chhnang, Kampong Cham, Tbong Khmum, Battambang, and Pailin. PHB focuses on two objectives:

## OBJECTIVE 1: STRENGTHENED PUBLIC SECTOR SYSTEMS FOR OVERSIGHT AND COORDINATION OF SBC AT NATIONAL AND PROVINCIAL LEVELS

**NCHP's Website and SBC Digital Library:** PHB supported the National Center for Health Promotion (NCHP), the project's primary RGC partner, to redesign its website and develop an SBC digital library. The new SBC digital library, linked to NCHP's website, is a user-friendly, searchable repository of SBC materials, tools, and studies available to all public and private SBC practitioners, researchers, and academics. PHB continues to provide coaching and support to NCHP staff with managing the website and promoting and expanding the content of the digital library.

**Social and Behavior Change (SBC) Forum:** PHB provided technical support to the National Center for Health Promotion (NCHP), to restart its SBC Forums designed to gain and share knowledge and best practices regarding health-related SBC programming. These semi-annual forums bring together SBC practitioners from across Cambodia to discuss relevant SBC topics, challenges, and innovations as part of NCHP's leadership role in coordinating SBC activities in Cambodia.

**SBC Practitioner's Guidelines:** The Guidelines, developed with NCHP, serves as a framework for promoting sound, evidence-based SBC programming among SBC partners and practitioners in Cambodia. The SBC Practitioner's Guidelines also includes best practices for integrating gender within SBC design and implementation and will serve as an important resource for promoting gender equality.

The SBC Practitioner's Guidelines, which was produced via a highly consultative process with national and sub-national partners, was approved by the Ministry of Health (MoH) in June 2022.

## OBJECTIVE 2: IMPROVED ABILITY OF INDIVIDUALS TO ADOPT HEALTHY BEHAVIORS

**Family Planning SBC Activity:** Working with local implementing partners Partners in Compassion (PC), AHEAD and KHEMARA, PHB aims to increase knowledge of modern methods (MMs) of contraception, change perceptions around MMs, and drive increased MM use for family planning (FP) among couples. PHB also implements a youth-focused SBC intervention called "Just the Two of Us" designed to resonate with technology-savvy young people. Partnering with Dosslab, a social media platform that promotes youth wellbeing, the intervention aims to change young people's misconceptions around sexual and reproductive health and see modern contraception as a means to plan their future and achieve their ambitions.

**Tuberculosis SBC Activity:** Working with local implementing partners PC and AHEAD, PHB promotes TB testing and treatment, especially among at-risk elderly populations. Under the umbrella concept of "If You Love Me...", this community-based SBC activity builds on the desire to protect your loved ones and encourages family and community members to 1) seek TB testing based on symptoms, and 2) complete a full course of treatment for those who test positive.

**WASH SBC Activity:** Working with local implementing partner PC, KHEMRA and AHEAD, PHB helps to reduce diarrheal disease by making it easier for rural households to wash their hands at 5 critical times and to safely treat and store drinking water. The overarching concept for the intervention is "What looks clean might not be safe", addressing key misconceptions about handwashing and facilitating access to handwashing stations and safe water storage. This activity was phased out in 2023.

**Maternal & Child Health and Nutrition SBC Activity:** PHB launched its innovative MCH & Nutrition activity to promote mother and child health during pregnancy and early childhood. Using interactive voice response (IVR) digital technology, PHB provides ongoing advice and support to pregnant women and new mothers on how to help them and their babies stay healthy and prosper.

**Malaria SBC Activity:** In collaboration with National Center for Parasitology, Entomology and Malaria Control (CNM), PHB implements the activity in Kampong Speu and Kampong Chhnang to encourage forest-goers to get tested for malaria before re-entering the community.

**Non-Communicable Diseases SBC Activity:** By utilizing social media and community events, the intervention aims to increase accurate risk appraisal and interrupt behavioral patterns to help women establish new habits around diet and physical activity. It also re-balances cost-benefit analysis around screening by promoting the benefits of early diagnosis and high-quality client education.

**Perception of Quality Healthcare (PQH):** The purpose of the intervention is to encourage Cambodians to behave as an "informed consumer", actively engaging with their health care provider regarding their symptoms and treatment, which results in better medical care, diagnosis, and adherence. This digital campaign called "3 Go, 3 Follow" uses Facebook reels, videos, and static posts to reach middle class Cambodians aged 25-45 in urban areas.

### CONTACT INFORMATION

Jim Malster
Chief of Party, Promoting Healthy Behaviors
Email: jmalster@psi.org

Dr. Sam Sochea
Project Management Specialist, USAID Cambodia
Email: ssam@usaid.gov

**FOR MORE INFORMATION:**
usaid.gov/cambodia



# គម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព (PHB)

គម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព (PHB) គឺជាគម្រោងផ្លាស់ប្តូរឥរិយាបថបុគ្គលនិងសង្គម ដែលចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៨ ឧបត្ថម្ភថវិកាដោយទីភ្នាក់ងារជំនួយអាមេរិក USAID។ គោលដៅរបស់គម្រោងនេះ គឺដើម្បីធ្វើឲ្យប្រសើរឡើង នូវឥរិយាបថសុខភាពក្នុងចំណោមប្រជាជនកម្ពុជា និងធានាឲ្យបានថា ប្រជាជនកម្ពុជាស្វែងរក និងទទួលបានសេវាសុខភាព ដែលប្រកបដោយគុណភាព ដោយកាត់បន្ថយឧបសគ្គផ្នែកហិរញ្ញវត្ថុ។ ដំបូងឡើយ គម្រោង PHB ផ្តោតទៅលើវិស័យសុខភាពធំៗចំនួន៦ គឺ៖ សុខភាពមាតានិងទារក អាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ការពន្យារកំណើត ជំងឺរបេង និងជំងឺគ្រុនចាញ់។ ក្នុងឆ្នាំ២០២០ និង ២០២១ គម្រោង PHB បានអនុវត្តសកម្មភាពទាក់ទងនឹងជំងឺកូវីដ-១៩ ដើម្បីឆ្លើយតបនឹងការរីករាលដាលនៃជំងឺនេះ ។ នៅចុងឆ្នាំ២០២១ ជំងឺមិនឆ្លង ត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពរបស់គម្រោង ហើយរយៈពេលរបស់គម្រោងត្រូវបានបន្ត ដល់ឆ្នាំ ២០២៥។ គម្រោង PHB អនុវត្តដោយអង្គការអន្តរជាតិបំរើសុខភាពប្រជាជន (PSI) និងដៃគូ ដោយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា។ គម្រោង PHB អនុវត្តនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង កំពង់ចាម ត្បូងឃ្មុំ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ និងកំពង់ស្ពឺ។

## គោលបំណងទី១: ពង្រឹងប្រព័ន្ធវិស័យសាធារណៈ ដើម្បីធ្វើការត្រួតពិនិត្យនិងសម្របសម្រួល ទាក់ទងសកម្មភាពផ្លាស់ប្តូរឥរិយាបថបុគ្គលនិងសង្គម នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

**វេបសាយ និងបណ្ណាល័យឌីជីថល របស់ NCHP:** គម្រោង PHB គាំទ្រដល់មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព (NCHP) ដែលជាដៃគូរដ្ឋាភិបាលចំបងរបស់គម្រោង ដើម្បីកែលម្អវេបសាយ និងបង្កើតបណ្ណាល័យឌីជីថល SBC របស់មជ្ឈមណ្ឌល។ បណ្ណាល័យឌីជីថលថ្មីនេះ គឺជាឃ្លាំងផ្ទុកឯកសារ សម្ភារ និងអត្ថបទស្រាវជ្រាវ ដែលងាយប្រើ ហើយអ្នកអនុវត្តកិច្ចការ SBC អ្នកស្រាវជ្រាវ និងបញ្ញវន្ត ទាំងនៅក្នុងវិស័យសាធារណៈ និងឯកជន អាចចូលទាញយកឯកសារទាំងនោះបាន។ គម្រោង PHB នៅបន្តផ្តល់ការប្រឹក្សានិងគាំទ្រ ដល់បុគ្គលិក NCHP ក្នុងការគ្រប់គ្រង និងបង្កើនឯកសារបន្ថែមដល់បណ្ណាល័យឌីជីថលនេះ។

**វេទិកាផ្លាស់ប្តូរឥរិយាបថបុគ្គលនិងសង្គម (SBC):** គម្រោងបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដល់ NCHP ដើម្បីចាប់ផ្តើមដំណើរការវេទិកានេះឡើងវិញ ដែលវេទិកានេះត្រូវបានរៀបចំឡើងដើម្បីទទួលនិងចែលរំលែកចំណេះដឹងនិងបទពិសោធន៍ ទាក់ទងនឹងការបង្កើតកម្មវិធី SBC និងជាការជួបជុំគ្នារវាងអ្នកអនុវត្តកិច្ចការ SBC នៅប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីប្រធានបទដែលពាក់ព័ន្ធ ការប្រឈម និងគំនិតច្នៃប្រឌិត ដែលជាផ្នែកមួយនៃតួនាទីជាអ្នកដឹកនាំរបស់ NCHP ក្នុងការសម្របសម្រួលសកម្មភាព SBC នៅកម្ពុជា។

**សេចក្តីណែនាំសម្រាប់អ្នកអនុវត្តសម្មភាពផ្លាស់ប្តូរឥរិយាបថបុគ្គលនិងសង្គមដើម្បីសុខភាព:** សេចក្តីណែនាំនេះ ដែលរៀបរៀងឡើងដោយ NCHP គឺជាគោលការណ៍នៃការលើកកម្ពស់ការបង្កើតកម្មវិធី SBC ដែលល្អ និងផ្អែកទៅលើភស្តុតាង ក្នុងចំណោមស្ថាប័នដៃគូនិងអ្នកអនុវត្តកិច្ចការ SBC ក្នុងប្រទេសកម្ពុជា។ សេចក្តីណែនាំនេះក៏មានការដាក់បញ្ចូលបទពិសោធន៍សម្រាប់បញ្ច្រាបយេនឌ័រ ទៅ

ក្នុងការបង្កើតនិងអនុវត្តការងារ SBC និងជាធនធានដ៏សំខាន់សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ។ សេចក្តីណែនាំនេះ ត្រូវបានរៀបរៀងឡើងដោយមានដំណើរការប្រឹក្សាដ៏ល្អិតល្អន់ ជាមួយដៃគូថ្នាក់ជាតិនិងក្រោមជាតិ និងត្រូវបានអនុម័តយល់ព្រមដោយក្រសួងសុខាភិបាលនៅខែមិថុនា ឆ្នាំ២០២២។

## គោលបំណងទី២: បង្កើនលទ្ធភាពរបស់បុគ្គល ក្នុងការទទួលយកឥរិយាបថ ដែលនាំមកនូវសុខភាពល្អ

**សកម្មភាព SBC ទាក់ទងនឹងការពន្យារកំណើត:** ដោយធ្វើការជាមួយអង្គការដៃគូក្នុងស្រុក គឺអង្គការ PC អង្គការ AHEAD និងអង្គការខេមរា គម្រោង PHB ជួយបង្កើនចំណេះដឹង និងផ្លាស់ប្តូរការយល់ខុសជុំវិញការពន្យារកំណើតបែបទំនើប (MMs) ព្រមទាំងបង្កើនការប្រើប្រាស់ MMs ។ សកម្មភាព SBC នេះមានគោលបំណង ១) ច្រានចោលការយល់ខុសនិងមិនពិត ជុំវិញការពន្យារកំណើតបែបទំនើប ២) លើកទឹកចិត្តឲ្យដៃគូពិភាក្សានិងធ្វើការសម្រេចចិត្តរួមគ្នាទាក់ទងនឹងការពន្យារកំណើត និង 3) នាំឲ្យមានការចូលរួមពីបុរស ស្តីពីអត្ថប្រយោជន៍នៃការពន្យារកំណើត និងលើកទឹកចិត្តឲ្យពួកគាត់ជជែកជាមួយដៃគូ អំពី MMs ។ សម្រាប់ភ្នំពេញក្រុមគោលដៅគឺជាមនុស្សវ័យក្មេង ដូចច្នេះយុទ្ធនាការផ្សេងមួយដែលមានឈ្មោះថា "ពីរនាក់បានហើយ" ដែលលើកកម្ពស់សុខុមាលភាពរបស់យុវជនយុវនារី យុទ្ធនាការនេះមានគោលបំណងផ្លាស់ប្តូរការយល់ឃើញខុស របស់ប្រជាជនវ័យក្មេងទាំងនេះ ជុំវិញសុខភាពបន្តពូជ និងការពន្យារកំណើតបែបទំនើប។

**សកម្មភាព SBC ស្តីពីជំងឺរបេង:** ដោយធ្វើការជាមួយអង្គការដៃគូ គឺអង្គការ AHEAD និងអង្គការ PC គម្រោង PHB លើកកម្ពស់ការទៅធ្វើតេស្ត និងព្យាបាលជំងឺរបេង ជាពិសេសនៅក្នុងចំណោមក្រុមគោលដៅដែលងាយរងគ្រោះ។ ក្រោមយុទ្ធនាការដែលមានឈ្មោះថា "បើស្រលាញ់ខ្ញុំពិត..." សកម្មភាពនៅថ្នាក់សហគមន៍នេះ ប្រើប្រាស់ការចង់ការពារមនុស្សជាទីស្រលាញ់ និងការលើកទឹកចិត្តពីសំណាក់គ្រួសារ និងសមាជិកសហគមន៍ ដើម្បី ១) ទៅរកការធ្វើតេស្តទៅតាមរោគសញ្ញា និង ២) ទទួលការព្យាបាលរហូតដល់ជាសះស្បើយពេញលេញ សម្រាប់អ្នកដែលបានលទ្ធផលវិជ្ជមានពីការធ្វើតេស្ត ។

**សកម្មភាព SBC ស្តីពីទឹកស្អាតនិងអនាម័យ:** ដោយធ្វើការជាមួយអង្គការដៃគូក្នុងស្រុក គឺអង្គការខេមរា គម្រោង PHB ជួយដល់ការកាត់បន្ថយជំងឺរាគរូស តាមរយៈការជួយឲ្យគ្រួសារនៅតាមជនបទ លាងដៃនៅពេលសំខាន់ៗទាំង៥ ព្រមទាំងចម្អិនឬចំរោះនិងរក្សាទុកទឹក ដោយសុវត្ថិភាព។ ក្រោមយុទ្ធនាការ "មើលឃើញស្អាត មិនប្រាកដថាមានសុវត្ថិភាព" គម្រោងលើកអំពីការយល់ខុសអំពីពេលវេលាដែលត្រូវលាងដៃ និងជួយសម្របសម្រួលដល់ការនាំឲ្យមានកន្លែងលាងដៃ និងកន្លែងទុកដាក់ទឹកដោយសុវត្ថិភាព។

**សកម្មភាព SBC ស្តីពីការគាំពារមាតានិងទារក និងអាហារូបត្ថម្ភ:** គម្រោង PHB បានចាប់ផ្តើមសកម្មភាពគាំពារមាតានិងទារក/អាហារូបត្ថម្ភ ដើម្បីលើកកម្ពស់សុខភាពម្តាយនិងកូន ក្នុងអំឡុងពេលមានផ្ទៃពោះ និងដំណាក់កាលដំបូងនៃជីវិតទារក។ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល នៃប្រព័ន្ធសំលេងស្វ័យប្រវត្តិ (IVR) គម្រោង PHB ផ្តល់ ដំបូន្មានបន្តបន្ទាប់ និងការគាំទ្រ ដល់ស្ត្រីមានផ្ទៃពោះនិងស្ត្រីទើបសម្រាលកូន អំពីការជួយឲ្យពួកគាត់និងកូន មានសុខភាព និងការលូតលាស់ល្អ។

**សកម្មភាព SBC ស្តីពីជំងឺគ្រុនចាញ់:** ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រនិងបាណកសាស្ត្រ (CNM) គម្រោងបានផ្សព្វផ្សាយ ក្រើនរំលឹកដល់អ្នកដើរព្រៃឱ្យធ្វើតេស្តរកមេរោគគ្រុនចាញ់ជាមួយ VMWs មុនចូលក្នុងសហគមន៍វិញ។

**សកម្មភាព SBC ស្តីពីជំងឺមិនឆ្លង:** ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីនៅតាមសហគមន៍ គម្រោងបានបង្កើនការយល់ដឹងអំពីហានិភ័យ និងកត្តារាំងស្ទះនៃឥរិយាបថដើម្បីលើកទឹកចិត្តឱ្យស្ត្រីបង្កើតទម្លាប់ថ្មីជុំវិញរបបអាហារ និងសកម្មភាពរាងកាយ ព្រមទាំងលើកកម្ពស់អត្ថប្រយោជន៍នៃការទៅធ្វើរោគវិនិច្ឆ័យឱ្យបានឆាប់រហ័ស ។

**សកម្មភាព SBC ស្តីពីការថែទាំសុខភាពប្រកបដោយគុណភាព:** គម្រោង PHB ចង់ឱ្យប្រជាជនកម្ពុជានៅទីក្រុង យល់ឃើញថាអតិថិជនដែលយល់ដឹង ធ្វើការចូលរួមនៅក្នុងការពិគ្រោះសុខភាពជុំវិញរោគសញ្ញារបស់ខ្លួន ដើម្បីការថែទាំសុខភាពប្រកបដោយគុណភាព មានលក្ខណៈស្របទៅនឹងការព្យាបាលប្រកបដោយភស្តុតាង។ សកម្មភាពនេះ ប្រើប្រាស់ហ្វេសប៊ុកជាវេទិកាចំបង ដោយផ្តោតលើប្រជាជនកម្ពុជាដែលមានចំណូលមធ្យម អាយុពី២៥-៤៥ ឆ្នាំ នៅតំបន់ទីក្រុង។


**ព័ត៌មានទំនាក់ទំនង**

លោក ជីម ម៉ាល់ស្ទើរ
ប្រធានគម្រោងលើកកម្ពស់ឥរិយាបថប្រកបដោយសុខុមាលភាព
Email: jmalster@psi.org

វេជ្ជ. សំ សុជា
អ្នកជំនាញផ្នែកគ្រប់គ្រងគម្រោង នៃទីភ្នាក់ងារ USAID
Email: ssam@usaid.gov

ព័ត៌មានបន្ថែម: usaid.gov/cambodia